# ច្បាប់

# ស្តីពី

# ការបោះឆ្នោតជ្រើសរើស

# ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត

# ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

ROYAUME DU CAMBODGE
LE MINISTERE DU PALAIS ROYAL

# ព្រះរាជក្រម

នស/រកម/០៥០៨/០១៧

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ បានអនុម័តកាលពីថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំរដ្ឋសភា លើកទី ៧ នីតិកាលទី ៣ និងដែលព្រឹទ្ធសភា បានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០០៨ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី ៤ នីតិកាលទី ២ ហើយក្រុមប្រឹក្សាធម្មនុញ្ញបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ០៩៧/០០២/២០០៨ កបធ.ច ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៨ ដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលដៅកំណត់ការរៀបចំ ការគ្រប់គ្រងនិងការប្រព្រឹត្តទៅនៃការបោះឆ្នោតអសកល ដើម្បីជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ហើយដែលក្នុងច្បាប់នេះហៅកាត់ថា "ក្រុមប្រឹក្សា" ។

**មាត្រា ២.-**

ក្រុមប្រឹក្សាមានអាណត្តិប្រាំ(០៥)ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលក្រុមប្រឹក្សាថ្មីចូលកាន់តំណែង ។

អាណត្តិរបស់ក្រុមប្រឹក្សា ត្រូវគិតចាប់ពីថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងផុតកំណត់នៅថ្ងៃបោះឆ្នោតបន្ទាប់ ។

**មាត្រា ៣.-**

បទប្បញ្ញត្តិដូចមានចែងនៅក្នុងមាត្រា ១៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវយកមកអនុវត្តសម្រាប់កំណត់ចំនួនសមាជិកក្រុមប្រឹក្សានីមួយៗ ។

**មាត្រា ៤.-**

សមាជិកក្រុមប្រឹក្សាត្រូវជ្រើសរើសឡើង ដោយការបោះឆ្នោតអសកល មិនចំពោះ ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ តាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។

**មាត្រា ៥.-**

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវធ្វើតែមួយថ្ងៃ នៅថ្ងៃអាទិត្យណាមួយ ។

កាលបរិច្ឆេទជាក់ស្តែងនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាត្រូវកំណត់ដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ក្នុងករណីដែលសមាជិកទាំងអស់របស់ក្រុមប្រឹក្សាណាមួយលាលែងពីមុខតំណែង ឬត្រូវបានរំលាយក្នុងកំឡុងពេលនៃអាណត្តិរបស់ក្រុមប្រឹក្សា គណៈកម្មាធិការជាតិរៀបចំការ

**មាត្រា ១១.–**

ក្នុងករណីចាំបាច់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាចបង្កើតគណៈកម្មការរៀបចំការបោះឆ្នោតសម្រាប់រាជធានី ឬ ខេត្ត ឬ ក្រុង ឬ ស្រុក ឬ ខណ្ឌ ។

**មាត្រា ១២.–**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវរៀបចំតាក់តែងបទបញ្ញាតិនិងនីតិវិធីដែលទាក់ទងទៅនឹងការគ្រប់គ្រងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ដោយអនុលោមទៅតាមគោលការណ៍នៃច្បាប់នេះ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

## ផ្នែកទី ២
## ប្រព័ន្ធបោះឆ្នោត និងរូបមន្ត

**មាត្រា ១៣.–**

**ក.** ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវអនុវត្តតាមប្រព័ន្ធបោះឆ្នោតសមាមាត្រ ដោយត្រូវបែងចែកអាសនៈតាមរូបមន្តមធ្យមភាគខ្ពស់បំផុត ដែលផ្អែកលើចំនួនអាសនៈ និងលទ្ធផលនៃការបោះឆ្នោតតាមមណ្ឌល តាមជំហានទាំងឡាយដូចខាងក្រោម :

**ជំហានទី ១** : កំណត់ចំនួនកូតាដែលតម្រូវឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយទទួលបានអាសនៈមួយដោយយកចំនួនសន្លឹកឆ្នោតបានការសរុបមកចែកនឹងចំនួនអាសនៈសរុបរបស់ក្រុមប្រឹក្សា តាមរូបមន្តដូចខាងក្រោម :

$$\text{ក}_{\text{ក}} = \frac{\text{ស}_{\text{ស}}}{\text{អ}_{\text{ស}}}$$

ក្នុងនោះ :

-$\text{ក}_{\text{ក}}$ : តាងឱ្យកូតាជាផលចែកដែលត្រូវគិតដល់ ២ ខ្ទង់ក្រោយក្បៀស ។

-$\text{ស}_{\text{ស}}$ : តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុបដែលបានបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ ដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា។

-$អ_{ស}$ : តាងឱ្យចំនួនអាសនៈសរុបនៅក្នុងក្រុមប្រឹក្សា ។

**ជំហានទី ២:** កំណត់ចំនួនអាសនៈជាបឋមដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ បានទទួលនៅក្នុងក្រុមប្រឹក្សា ។

រូបមន្តដូចខាងក្រោម ត្រូវអនុវត្តដាច់ដោយឡែកពីគ្នាសម្រាប់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា :

$$អ_{ន} = \frac{ស_{ប}}{ក_{ត}}$$

ក្នុងនោះ :

-$អ_{ន}$ :ជាផលចែកដោយមិនគិតសំណល់ចែកតាងឱ្យចំនួនអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗមានសិទ្ធិបានទទួលមុនពេលធ្វើប្រមាណវិធីចាំបាច់ណាមួយនៅក្នុងជំហានទី ៣ ។

-$ស_{ប}$: តាងឱ្យចំនួនសន្លឹកឆ្នោតបានការដែលបានបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយដែលបានចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

-$ក_{ត}$ : តាងឱ្យកូតាដែលបានកំណត់នៅក្នុងជំហានទី ១ ។

បន្ទាប់ពីគណនាគ្រប់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ ដែលបានចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ក្នុងជំហានទី ២ ហើយប្រសិនគ្មានអាសនៈនៅសល់ដើម្បីបែងចែកបន្តទៀតនោះ ចំនួនអាសនៈសម្រេចត្រូវកំណត់យកតែម្តង ។

ក្នុងករណីមានអាសនៈនៅសល់ត្រូវបន្តបែងចែក បន្ទាប់ពីធ្វើការគណនាសម្រាប់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ ដែលបានចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អាសនៈដែលនៅសល់ទាំងនេះត្រូវកំណត់ទៅតាមរបៀបដែលបានកំណត់ក្នុងជំហានទី ៣ ។

**ជំហានទី ៣:** អាសនៈដែលនៅសល់ ត្រូវបែងចែកឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ ដែលមានសិទ្ធិទទួលបាននៅក្នុងក្រុមប្រឹក្សា ដោយកំណត់យកមធ្យមភាគច្រើនបំផុត ។

រូបមន្តដូចខាងក្រោម ត្រូវអនុវត្តដាច់ដោយឡែកពីគ្នាសម្រាប់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗដែលបានចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា :

$$ម_{ន} = \frac{ស_{ឆ}}{អ_{ន}+១}$$

ក្នុងនោះ :

-$ម_{ន}$ : តាងឱ្យមធ្យមភាគខ្ពស់បំផុត ។

-$ស_{ឆ}$ : តាងឱ្យចំនួនសន្លឹកឆ្នោតបានការដែលបានបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ ។

-$អ_{ន}$ : តាងឱ្យចំនួនអាសនៈដែលបានបែងចែកឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ ។

ក្នុងករណីនៅសល់អាសនៈចំនួនមួយដែលត្រូវបែងចែក បន្ទាប់ពីបានគណនាតាមរូបមន្តក្នុងជំហានទី ៣ សម្រាប់បញ្ជីបេក្ខជននៃគណបក្សនយោបាយដែលមានលក្ខណ-សម្បត្តិទាំងអស់ អាសនៈនោះត្រូវបែងចែកទៅឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលមានមធ្យមភាគខ្ពស់បំផុត ។

ក្នុងករណីនៅសល់អាសនៈច្រើនជាងមួយដែលត្រូវបែងចែក ត្រូវអនុវត្តតាមរូបមន្តក្នុងជំហានទី ៣ ហើយអាសនៈចំនួនមួយត្រូវបែងចែកទៅឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយណាដែលមានមធ្យមភាគខ្ពស់បំផុត ។ បន្ទាប់មកត្រូវអនុវត្តតាមរូបមន្តនេះម្តងទៀត ដោយបន្ថែមតម្លៃ $អ_{ន}$ ចំនួន ១ ចំពោះបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលបានទទួលអាសនៈចំនួនមួយក្នុងការអនុវត្តរូបមន្តលើកទីមួយ ។ ដូច្នេះអាសនៈចំនួនមួយ ត្រូវផ្តល់ទៅឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលមានមធ្យមភាគខ្ពស់បំផុតក្នុងការអនុវត្តរូបមន្តលើកទីពីរ ។ ក្នុងករណីនៅសល់អាសនៈត្រូវបែងចែកបន្តទៀតនោះ ការគណនាត្រូវធ្វើតាមរបៀបដដែល ដោយបែងចែកម្តងមួយអាសនៈ ជាបន្តបន្ទាប់រហូតដល់អស់អាសនៈដែលនៅសល់ ។

**ខ.** ការប្រកាសបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សា ត្រូវអនុលោមទៅតាមបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត និងអនុវត្តតាមលំដាប់លេខរៀងដូចមានចែងក្នុងមាត្រា ២១ នៃច្បាប់នេះ ។

**គ.** ប្រសិនបើក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាមានអ្នកជាប់ឆ្នោតទទួលមរណភាព ឬ លាលែង ឬ ប្រាសចាកពីបេក្ខភាពសមាជិកក្រុមប្រឹក្សា បេក្ខជនដែលមានឈ្មោះបន្ទាប់នៅក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនោះ ត្រូវបានប្រកាសថាជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សារបស់សាមីគណបក្សនយោបាយ ។

**ឃ.** ក្នុងករណីបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយ មានបេក្ខជនមិនគ្រប់គ្រាន់ដោយមូលហេតុដូចមានចែងក្នុងចំណុច **គ** នៃមាត្រានេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវស្នើជាលាយលក្ខណ៍អក្សរទៅសាមីគណបក្សនយោបាយនោះឱ្យបន្ថែមឈ្មោះក្នុងបញ្ជីបេក្ខជនក្នុងរយៈពេលដប់បួន (១៤) ថ្ងៃ ក្រោយពីទទួលបានសំណើ ។

បែបបទនៃការទទួលពិនិត្យ និងអនុម័តបេក្ខជនដែលស្នើបន្ថែមនេះ ត្រូវអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ១៥ ដល់មាត្រា ១៨ មាត្រា ២០ មាត្រា ២២ ដល់មាត្រា ២៦ នៃច្បាប់នេះ ។

ក្នុងករណីគណបក្សនយោបាយណាមួយ មិនបានអនុវត្តតាមពេលវេលាកំណត់ខាងលើ ឬ មិនបានកែលម្អការខ្វះខាត ដែលធ្វើឱ្យគណបក្សនយោបាយនោះមិនអាចបំពេញអាសនៈដែលនៅទំនេរបាន ត្រូវចាត់ទុកដូចជាគណបក្សនយោបាយនោះបោះបង់ចោលអាសនៈឱ្យនៅទំនេរ ។

**ង.** ក្នុងករណីគណបក្សនយោបាយណាមួយបោះបង់ចោលអាសនៈ ដែលខ្លួនទទួលបាន គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបែងចែកអាសនៈដែលបោះបង់ចោលនោះ ទៅឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយផ្សេងទៀតដែលមានអាសនៈនៅក្នុងក្រុមប្រឹក្សា ក្នុងអំឡុងពេលយ៉ាងយូរដប់បួន (១៤) ថ្ងៃ ដោយធ្វើប្រមាណវិធីតាមជំហានទាំងឡាយដូចខាងក្រោម :

**ជំហានទី ១** : កំណត់ចំនួនកូតាដែលតម្រូវឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយទទួលបានមួយអាសនៈ តាមរូបមន្តដូចខាងក្រោម :

ROYAUME du CAMBODGE
LE MINISTRE du PALAIS ROYAL

$$\text{ក}'_{\text{ត}} = \frac{\text{ស}'_{\text{ស}}}{\text{អ}'_{\text{ប}}}$$

ក្នុងនោះ :

-$\text{ក}'_{\text{ត}}$ : តាងឱ្យ កូតាជាផលចែកដែលត្រូវគិតដល់២ខ្ទង់ក្រោយក្បៀស ។

-$\text{ស}'_{\text{ស}}$ : តាងឱ្យ ចំនួនសន្លឹកឆ្នោតបានការសរុបដែលបានបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ ដែលបានទទួលអាសនៈក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ដកចេញនូវចំនួនសន្លឹកឆ្នោតបានការសរុបបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលបានបោះបង់ចោលអាសនៈនៅក្នុងក្រុមប្រឹក្សា ។

-$\text{អ}'_{\text{ប}}$ : តាងឱ្យ ចំនួនអាសនៈដែលបានបោះបង់ចោលនៅក្នុងក្រុមប្រឹក្សា ។

**ជំហានទី ២** : កំណត់ចំនួនអាសនៈជាបឋមដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗបានទទួល តាមរូបមន្តដូចខាងក្រោម :

$$\text{អ}'_{\text{ន}} = \frac{\text{ស}_{\text{ប}}}{\text{ក}'_{\text{ត}}}$$

ក្នុងនោះ :

-$\text{អ}'_{\text{ន}}$ :តាងឱ្យ ចំនួនអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយបានទទួលមុនពេលធ្វើប្រមាណវិធីចាំបាច់ណាមួយក្នុងជំហានទី ៣ ។

-$\text{ស}_{\text{ប}}$ : តាងឱ្យ ចំនួនសន្លឹកឆ្នោតបានការសរុបបោះឱ្យបញ្ជីបេក្ខជននៃគណ-បក្សនយោបាយមួយ ។

-$\text{ក}'_{\text{ត}}$ : តាងឱ្យ កូតាដែលបានកំណត់ក្នុងជំហានទី ១ ។

បន្ទាប់ពីបានធ្វើការគណនាក្នុងជំហានទី ២ សម្រាប់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ដែលទទួលបានអាសនៈក្នុងក្រុមប្រឹក្សា លើកលែងតែបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលបោះបង់ចោលអាសនៈក្នុងក្រុមប្រឹក្សា ក្នុងករណីគ្មានអាសនៈទៀតសម្រាប់ដើម្បីបែងចែកបន្តទៀត ចំនួនអាសនៈសម្រេចត្រូវកំណត់យកតែម្តង ។

ក្នុងករណីគណនាក្នុងជំហានទី ២ រួចហើយ ប៉ុន្តែមានអាសនៈនៅសល់ដែលត្រូវបន្តបែងចែកតទៀត អាសនៈដែលនៅសល់នោះត្រូវបែងចែកតាមរូបមន្តដែលបានកំណត់ក្នុងជំហានទី ៣ ។

**ជំហានទី ៣ :** អាសនៈដែលនៅសល់ត្រូវបានបែងចែកដោយកំណត់យកមធ្យមភាគខ្ពស់បំផុតតាមរូបមន្តដូចខាងក្រោម :

$$ម'_{ន} = \frac{ស_{ប}}{អ'_{ន}+១}$$

ក្នុងនោះ :

-**ម'ន** : តាងឱ្យមធ្យមភាគខ្ពស់បំផុត ។

-**សប** : តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុបបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយក្នុងក្រុមប្រឹក្សា ។

-**អ'ន**: តាងឱ្យចំនួនអាសនៈដែលបានបែងចែកឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ ។

វិធីសាស្ត្រដូចមានចែងក្នុងវាក្យខ័ណ្ឌទី ៩ និងទី ១០ ចំណុច **ក** នៃមាត្រានេះ ត្រូវអនុវត្តចំពោះការគណនាក្នុងជំហានទី ៣ និងការគណនាជាបន្តបន្ទាប់ទៀត ។

**ច.** ក្នុងករណីគណនាតាមរូបមន្តខាងលើ មានលទ្ធផលស្មើគ្នារវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយចំនួន ដែលមិនអាចកំណត់ឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយបានទទួលអាសនៈដែលត្រូវបែងចែកគណៈកម្មការរាជធានី ឬ គណៈកម្មាធិការខេត្ត រៀបចំការបោះឆ្នោត ត្រូវអនុវត្តវិធីចាប់ឆ្នោត ដើម្បីកំណត់យកបញ្ជីបេក្ខជននៃគណបក្សនយោបាយឈ្នះឆ្នោត ។

វិធីចាប់ឆ្នោតត្រូវដំណើរការតាមនីតិវិធីដែលកំណត់ដោយបទបញ្ជារបស់គណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**ឆ.** ក្នុងករណីគណបក្សនយោបាយណាមួយទទួលបានអាសនៈបន្ថែមមួយ ឬ ច្រើន ប៉ុន្តែបញ្ជីបេក្ខជនរបស់ខ្លួនមានបេក្ខជនតិចជាងអាសនៈនោះ ត្រូវអនុវត្តតាមនីតិវិធីដូចមានចែងក្នុងចំណុច **ឃ** នៃច្បាប់នេះ ។

**ង.** ផ្អែកតាមលទ្ធផលនៃការបោះឆ្នោតដូចមានចែងក្នុងចំណុច **ក** នៃមាត្រានេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាចធ្វើការប្រកាសលទ្ធផលនៃការបោះឆ្នោតតាមមណ្ឌលនីមួយៗជាបន្តបន្ទាប់ ។

**ឈ.** មុនពេលប្រកាសលទ្ធផលនៃការបោះឆ្នោតជាផ្លូវការ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធ្វើសេចក្តីរាយការណ៍ជូនគ្រប់តំណាងគណបក្សនយោបាយដែលចូលរួមនូវចំនួនសន្លឹកឆ្នោតសរុបដែលបានបោះពុម្ពសម្រាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាតាមប្រភេទនីមួយៗ ចំនួនសន្លឹកឆ្នោតដែលបានប្រើប្រាស់នៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាតាមប្រភេទនោះ និងចំនួនសន្លឹកឆ្នោតដែលនៅសល់តាមប្រភេទនោះ ។

### មាត្រា ១៤.-

មណ្ឌលបោះឆ្នោត សម្រាប់ជ្រើសរើសក្រុមប្រឹក្សារួមមាន :

-រាជធានី ខេត្ត ជាមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត

-ក្រុង ស្រុក ខណ្ឌ ជាមណ្ឌលបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ។

សមាជិកក្រុមប្រឹក្សា ត្រូវជ្រើសរើសចេញពីបញ្ជីបេក្ខជនរបស់គណបក្សនយោបាយដែលបានជាប់ឆ្នោតសម្រាប់ប្រភេទក្រុមប្រឹក្សាក្នុងមណ្ឌលនោះ ។

## ផ្នែកទី ៣

## ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ

### មាត្រា ១៥.-

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវបំពេញល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ២១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ១៦.-**

ជនគ្រប់រូបដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវបញ្ចូលឈ្មោះរបស់ខ្លួនទៅក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយ ។

បញ្ជីបេក្ខជននីមួយៗត្រូវរៀបចំដោយគណបក្សនយោបាយដែលបានចុះបញ្ជីត្រឹមត្រូវតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងច្បាប់ស្តីពីគណបក្សនយោបាយ ។

បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗត្រូវមានឈ្មោះបេក្ខជនតាមលំដាប់លេខរៀង និងត្រូវធានាឱ្យមានបេក្ខជនស្ត្រីចូលរួម និងមានឈ្មោះនៅលំដាប់លេខរៀងសមស្រប ក្នុងបញ្ជីបេក្ខជននោះ ។

**មាត្រា ១៧.-**

គ្មានសិទ្ធិឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា :

-សមាជិករដ្ឋសភា ព្រឹទ្ធសភា ក្រុមប្រឹក្សាធម្មនុញ្ញ រាជរដ្ឋាភិបាល និងចៅក្រម

-អភិបាល អភិបាលរង រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

-សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គណៈកម្មការរៀបចំការបោះឆ្នោត និងមន្ត្រី បុគ្គលិកបម្រើការងាររៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់

-មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ នគរបាលជាតិក្នុងមុខតំណែង

-មន្ត្រីបុគ្គលិករបស់ក្រុមប្រឹក្សាគ្រប់លំដាប់ថ្នាក់

-ជនដែលត្រូវបានផ្តន្ទាទោសដកសិទ្ធិបោះឆ្នោត

-ព្រះសង្ឃ ឬ បព្វជិតសាសនា ។

**មាត្រា ១៨.-**

មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ នគរបាលជាតិ កងយោធពលខេមរភូមិន្ទ មន្ត្រីបុគ្គលិករបស់ក្រុមប្រឹក្សាគ្រប់លំដាប់ថ្នាក់ដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោត

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

ជ្រើសរើសក្រុមប្រឹក្សា ត្រូវដាក់ពាក្យសុំច្បាប់ឈប់ពិសេសយ៉ាងតិចប្រាំពីរ(០៧)ថ្ងៃ មុនថ្ងៃបើកការឃោសនាបោះឆ្នោត រហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតជាផ្លូវការ ។

ប្រសិនបើសាមីខ្លួនជាប់ឆ្នោត ហើយមានបំណងចង់បម្រើការងារជាសមាជិកក្រុមប្រឹក្សានោះ សាមីខ្លួនត្រូវធ្វើពាក្យសុំតាមឋានានុក្រមទៅក្រសួង ឬ ស្ថាប័នសាមី ដើម្បីទៅបម្រើការងារ ក្រៅក្របខ័ណ្ឌដើមក្នុងរយៈពេលនៃអាណត្តិរបស់ក្រុមប្រឹក្សា ។ ក្នុងរយៈពេលនេះ សាមីខ្លួនមានសិទ្ធិឡើងថ្នាក់ ឬ ឋានន្តរសក្តិ និងរក្សាអតីតភាពការងារសម្រាប់ទទួលសោធននិវត្តន៍ ។

នៅពេលចប់អាណត្តិជាសមាជិកក្រុមប្រឹក្សា សាមីខ្លួនអាចសុំត្រឡប់មកបម្រើការងារនៅក្រសួង ឬ ស្ថាប័នដើមវិញ ប៉ុន្តែមុខងារ និងតំណែងអាស្រ័យដោយក្រសួង ឬ ស្ថាប័នជាអ្នកសម្រេច ។

**មាត្រា ១៩.-**

គណបក្សនយោបាយដែលបានចុះបញ្ជីស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ ហើយមានបំណងចូលរួមប្រកួតប្រជែងនៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវចាប់ផ្តើមចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត តាមនីតិវិធីដែលរៀបចំដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត យ៉ាងតិចប៉ែតសិប(៨០)ថ្ងៃមុនកាលបរិច្ឆេទនៃការបោះឆ្នោត ។

**មាត្រា ២០.-**

គណបក្សនយោបាយត្រូវចុះបញ្ជីឈរឈ្មោះបោះឆ្នោតដោយឡែកៗពីគ្នា សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាប្រភេទណាមួយដែលគណបក្សនយោបាយនោះមានបំណងចូលរួមប្រកួតប្រជែង ដោយភ្ជាប់ជាមួយឯកសារនានាតាមការកំណត់នៅក្នុងបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ២១.-**

បញ្ជីបេក្ខជននៃគណបក្សនយោបាយ ត្រូវមានបេក្ខជនពេញសិទ្ធិ និងបេក្ខជនបម្រុង

ដែលមានចំនួនបេក្ខជនយ៉ាងតិចពីរ(០២)ដង នៃចំនួនអាសនៈសម្រាប់ក្រុមប្រឹក្សាដែលគណបក្សនយោបាយនោះមានបំណងចូលរួមប្រកួតប្រជែង ដែលរៀបចំលេខរៀងតាមលំដាប់អាទិភាពពីខ្ពស់មកទាប តាមការកំណត់របស់គណបក្សនយោបាយ ។

**មាត្រា ២២.–**

បេក្ខជនម្នាក់ៗត្រូវមានសេចក្តីប្រកាសរបស់ខ្លួន ដែលយល់ព្រមឱ្យគណបក្សនយោបាយតែងតាំងខ្លួនជាបេក្ខជនដើម្បីឈរឈ្មោះសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

សេចក្តីប្រកាសខាងលើនេះ ត្រូវភ្ជាប់ជាមួយសំណុំឯកសារពាក្យសុំចុះបញ្ជីគណបក្សនយោបាយនីមួយៗ តាមការកំណត់របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

បេក្ខជនម្នាក់ត្រូវមានឈ្មោះក្នុងបញ្ជីបេក្ខជននៃគណបក្សនយោបាយតែមួយ និងមានសិទ្ធិឈរឈ្មោះជាបេក្ខជនសម្រាប់ក្រុមប្រឹក្សាតែមួយប៉ុណ្ណោះ ។

បេក្ខជនដែលមានឈ្មោះក្នុងបញ្ជីបេក្ខជនរបស់គណបក្សនយោបាយលើសពីមួយ ឬឈរឈ្មោះជាបេក្ខជនសម្រាប់ក្រុមប្រឹក្សាលើសពីមួយ ត្រូវប្រកាសថាបាត់សិទ្ធិឈរឈ្មោះជាបេក្ខជន ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ២៣.–**

ដើម្បីចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាជាផ្លូវការ គណបក្សនយោបាយត្រូវដាក់ពាក្យសុំតាមបែបបទកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មកគណៈកម្មការរាជធានីរៀបចំការបោះឆ្នោត ឬ គណៈកម្មការខេត្តរៀបចំការបោះឆ្នោត ក្នុងរយៈពេលប្រាំ(០៥)ថ្ងៃ គិតចាប់ពីថ្ងៃចាប់ផ្តើមចុះបញ្ជីដោយភ្ជាប់មកជាមួយ :

១-សេចក្តីចម្លងលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយ នៅក្រសួងមហាផ្ទៃមួយច្បាប់

២-ឈ្មោះគណបក្សនយោបាយជាអក្សរពេញជាអក្សរកាត់និងសញ្ញាសម្គាល់គណបក្សនយោបាយ

៣-អាសយដ្ឋាននៃទីស្នាក់ការកណ្តាលរបស់គណបក្សនយោបាយ និងអា-

សយដ្ឋានទីស្នាក់ការរបស់គណបក្សនយោបាយនៅតាមរាជធានី ឬ ខេត្ត ឬ ក្រុង ឬ ស្រុក ឬ ខណ្ឌ

៤-បញ្ជីរាយនាមបេក្ខជនឈរឈ្មោះបោះឆ្នោតតាមប្រភេទក្រុមប្រឹក្សានីមួយៗ

៥-សេចក្តីបញ្ជាក់អំពីការចុះឈ្មោះបោះឆ្នោតដោយអាជ្ញាធរឃុំ សង្កាត់ដែលសាមីខ្លួន បេក្ខជននោះបានចុះឈ្មោះបោះឆ្នោត

៦-សេចក្តីប្រកាសរបស់គណបក្សនយោបាយនីមួយៗថា ចូលរួមបោះឆ្នោត និងទទួលយកលទ្ធផលនៃការបោះឆ្នោតដែលប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ និងចូលរួមអនុវត្តតាមច្បាប់ស្តីពីការបោះឆ្នោត ច្បាប់ស្តីពីគណបក្សនយោបាយ ក្រមសីលធម៌ បទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

៧-សេចក្តីប្រកាសរបស់បេក្ខជនយល់ព្រមទទួលការតែងតាំងជាបេក្ខជនតាមមណ្ឌលរបស់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ។

**មាត្រា ២៤.-**

គណៈកម្មការរាជធានីរៀបចំការបោះឆ្នោត ឬគណៈកម្មការខេត្តរៀបចំការបោះឆ្នោត ត្រូវពិនិត្យសម្រេចលើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតក្នុងរយៈពេលយ៉ាងយូរប្រាំ(០៥)ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំ ។

ក្នុងករណីយល់ព្រមចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត គណៈកម្មការរាជធានីរៀបចំការបោះឆ្នោត ឬ គណៈកម្មការខេត្តរៀបចំការបោះឆ្នោត ត្រូវចេញលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជូនសាមីគណបក្សនយោបាយ ។

ក្នុងករណីគណៈកម្មការរាជធានីរៀបចំការបោះឆ្នោត ឬ គណៈកម្មការខេត្តរៀបចំការបោះឆ្នោតយល់ឃើញថា សំណុំលិខិតរបស់គណបក្សនយោបាយនោះពុំបានបំពេញលក្ខខណ្ឌណាមួយដែលមានចែងចាប់ពីមាត្រា ១៥ ដល់មាត្រា ២៣ នៃច្បាប់នេះ គណៈកម្មការរាជធានីរៀបចំការបោះឆ្នោត ឬ គណៈកម្មការខេត្តរៀបចំការបោះឆ្នោត ត្រូវជូនដំណឹងទៅសាមីគណបក្សនយោបាយនោះវិញដើម្បីបំពេញបន្ថែម ។

គណៈកម្មការរាជធានីរៀបចំការបោះឆ្នោត ឬ គណៈកម្មការខេត្តរៀបចំការបោះឆ្នោតពាក់ព័ន្ធមួយច្បាប់ និងរក្សាទុកឯកសារមួយច្បាប់ ។

គណៈកម្មការរាជធានីរៀបចំការបោះឆ្នោត ឬ គណៈកម្មការខេត្តរៀបចំការបោះឆ្នោត ត្រូវផ្តល់ការយល់ព្រមលើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនោះ ហើយចេញលិខិតបញ្ជាក់ការសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជូនគណបក្សនយោបាយសាមី ។

ក្នុងករណីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បដិសេធលើពាក្យបណ្តឹងតវ៉ា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវ ៖

-បំពេញបែបបទបដិសេធចុះហត្ថលេខា និងកាលបរិច្ឆេទ

-ផ្តល់សេចក្តីបដិសេធដល់គណបក្សនយោបាយសាមី ឬ តំណាងមួយច្បាប់ គណៈកម្មការរាជធានីរៀបចំការបោះឆ្នោត ឬ គណៈកម្មការខេត្តរៀបចំការបោះឆ្នោតពាក់ព័ន្ធមួយច្បាប់ និងរក្សាទុកជាឯកសារមួយច្បាប់ ។

សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជាសេចក្តីសម្រេចចុងក្រោយ ។

**មាត្រា ២៦.-**

បន្ទាប់ពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតសម្រេចចុងក្រោយលើបណ្តឹងតវ៉ានានាអំពីការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត គណៈកម្មការរាជធានីរៀបចំការបោះឆ្នោត ឬ គណៈកម្មការខេត្តរៀបចំការបោះឆ្នោត ត្រូវរៀបចំធ្វើការចាប់ឆ្នោតកំណត់យកលេខរៀងគណបក្សនយោបាយសម្រាប់ដាក់លើសន្លឹកឆ្នោត ។ នីតិវិធីនៃការចាប់ឆ្នោតត្រូវកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ គណៈកម្មការរាជធានីរៀបចំការបោះឆ្នោត ឬ គណៈកម្មការខេត្តរៀបចំការបោះឆ្នោត ត្រូវបិទផ្សាយបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតដែលបានចុះបញ្ជីរួចហើយ ក្នុងរយៈពេលយ៉ាងតិចសែសិបប្រាំ(៤៥)ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

# ផ្នែកទី ៤
# បញ្ជីបោះឆ្នោត

**មាត្រា ២៧.-**

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងមុខតំណែង គឺជាអ្នកបោះឆ្នោតសម្រាប់ការបោះឆ្នោតអសកល ជ្រើសរើសក្រុមប្រឹក្សា ។

**មាត្រា ២៨.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវរៀបចំបញ្ជីបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា។

បញ្ជីបោះឆ្នោតត្រូវមានបញ្ជាក់ពីសមាជិកភាពក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងមុខតំណែងនៃក្រុមប្រឹក្សាឃុំ សង្កាត់ជាក់លាក់នីមួយៗ ។

បែបបទ នីតិវិធីនៃការរៀបចំបញ្ជីបោះឆ្នោតខាងលើនេះ ត្រូវកំណត់ដោយបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ២៩.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្តល់សុពលភាពបញ្ជីបោះឆ្នោត ក្នុងរយៈពេលយ៉ាងតិចសាមសិបប្រាំ (៣៥) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

បញ្ជីបោះឆ្នោតដែលត្រូវបានផ្តល់សុពលភាពរួចហើយ គឺជាបញ្ជីបោះឆ្នោតជាផ្លូវការ មិនអាចកែប្រែបានឡើយ លើកលែងតែមានអ្នកបោះឆ្នោតណាម្នាក់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនោះទទួលមរណភាព ។

ក្នុងករណីមានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាម្នាក់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតទទួលមរណភាព ក្រសួងមហាផ្ទៃត្រូវបំពេញបែបបទផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នោះ ក្នុងរយៈពេលប្រាំពីរ (០៧) ថ្ងៃ យ៉ាងតិចមុនថ្ងៃបោះឆ្នោត ដើម្បីឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដាក់ជំនួសក្នុងបញ្ជីបោះឆ្នោត ។

**មាត្រា ៣០.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបិទផ្សាយបញ្ជីបោះឆ្នោតផ្លូវការសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ក្នុងរយៈពេលយ៉ាងតិចសាមសិប(៣០)ថ្ងៃ

មុនថ្ងៃបោះឆ្នោតនៅការិយាល័យបោះឆ្នោត និងនៅទីកន្លែងសាធារណៈណាមួយក្នុងមណ្ឌលបោះឆ្នោតតាមប្រភេទក្រុមប្រឹក្សា ។

**មាត្រា ៣១.-**

គណបក្សនយោបាយដែលបានអនុញ្ញាតឱ្យចុះបញ្ជីដើម្បីចូលរួមប្រកួតប្រជែងនៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អង្គការពាក់ព័ន្ធនានាមានសិទ្ធិស្នើសុំនិងទទួលបានច្បាប់ចម្លងនៃបញ្ជីបោះឆ្នោតផ្លូវការ ដោយបង់ថ្លៃត្រឹមតម្លៃដើមនៃការផលិតឯកសារនោះ ។

**មាត្រា ៣២.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធានាឱ្យមានបញ្ជីបោះឆ្នោតផ្លូវការឱ្យបានគ្រប់គ្រាន់ច្បាស់លាស់ និងត្រឹមត្រូវ នៅតាមការិយាល័យបោះឆ្នោតនីមួយៗ ។

**មាត្រា ៣៣.-**

ក្នុងការបោះឆ្នោតឡើងវិញដើម្បីជ្រើសរើសក្រុមប្រឹក្សាថ្មីជំនួសក្រុមប្រឹក្សាដែលត្រូវបានរំលាយ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវយកបញ្ជីបោះឆ្នោតផ្លូវការចុងក្រោយនៃមណ្ឌលនោះ មកធ្វើបច្ចុប្បន្នភាព ស្របតាមបទបញ្ញានិងនីតិវិធីរបស់ខ្លួនសម្រាប់ដំណើរការបោះឆ្នោត ។

**មាត្រា ៣៤.-**

ដើម្បីបោះឆ្នោតបាន អ្នកបោះឆ្នោតដែលមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតផ្លូវការត្រូវបង្ហាញដល់មន្ត្រីការិយាល័យបោះឆ្នោតនូវឯកសារបញ្ជាក់អត្តសញ្ញាណរបស់ខ្លួនតាមការកំណត់របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

## ផ្នែកទី ៥
## ការិយាល័យបោះឆ្នោត

**មាត្រា ៣៥.-**

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាត្រូវធ្វើឡើងនៅក្នុងការិយាល័យបោះឆ្នោតមួយ ឬច្រើន ។

**មាត្រា ៣៦.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបង្កើតនិងរៀបចំការិយាល័យបោះឆ្នោតមួយ ឬ ច្រើនសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា តាមប្រភេទក្រុមប្រឹក្សានីមួយៗ ។

ការិយាល័យបោះឆ្នោតនីមួយៗត្រូវទទួលខុសត្រូវតំបន់មួយដែលបានកំណត់ ។

ក្រុង ស្រុក ខណ្ឌ គឺជាការិយាល័យបោះឆ្នោត ។

ការិយាល័យបោះឆ្នោតមួយ អាចរួមបញ្ចូលឃុំ សង្កាត់ច្រើនជាងមួយ ។

**មាត្រា ៣៧.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអាចជ្រើសរើសអគារ ឬ កន្លែងតែមួយ សម្រាប់ប្រើប្រាស់ជាការិយាល័យបោះឆ្នោតមួយ ឬ ច្រើន ប្រសិនបើការរៀបចំនោះមិនមានការប៉ះពាល់ដល់សុចរិតភាពនៃការបោះឆ្នោត ។

ការិយាល័យបោះឆ្នោតពីរ ឬ ច្រើននៅក្នុងអគារ ឬ កន្លែងតែមួយ ត្រូវចាត់ចែងឱ្យមានការគ្រប់គ្រងដោយឡែកពីគ្នា ។

**មាត្រា ៣៨.-**

បញ្ជីឈ្មោះទីតាំងនៃការិយាល័យបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវបិទផ្សាយនៅតាមសាលាឃុំ សង្កាត់ និងនៅទីកន្លែងសាធារណៈណាមួយនៅក្នុងមណ្ឌលបោះឆ្នោត ក្នុងរយៈពេលយ៉ាងតិចសាមសិប(៣០)ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

**មាត្រា ៣៩.-**

គណបក្សនយោបាយដែលបានអនុញ្ញាតឱ្យចុះបញ្ជី ដើម្បីចូលរួមប្រកួតប្រជែងនៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា មានសិទ្ធិស្នើសុំនិងទទួលបាននូវបញ្ជីឈ្មោះទីតាំងរបស់ការិយាល័យបោះឆ្នោត ដោយបង់ថ្លៃត្រឹមតម្លៃដើមសម្រាប់ផលិតឯកសារនេះ ។

**មាត្រា ៤០.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធ្វើច្បាប់ចម្លងបញ្ជីឈ្មោះ ទីតាំង

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ការិយាល័យបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សានីមួយៗ មួយច្បាប់ជូនក្រសួងមហាផ្ទៃ ។

**មាត្រា ៤១.–**

ផ្អែកតាមច្បាប់នេះ និងបទប្បញ្ញត្តិដូចមានចែងក្នុងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវកំណត់ជាក់ស្តែងអំពីការរៀបចំ ការគ្រប់គ្រងនិងការប្រព្រឹត្តទៅនៃការិយាល័យបោះឆ្នោត នៅក្នុងបទបញ្ជានិងនីតិវិធីរបស់ខ្លួនបន្ថែមទៀត ។

## ជំពូកទី ៦

## ការឃោសនាបោះឆ្នោត

**មាត្រា ៤២.–**

បេក្ខជន និងគណបក្សនយោបាយដែលបានអនុញ្ញាតឱ្យចុះបញ្ជីគណបក្សនយោបាយឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា មានសិទ្ធិធ្វើការឃោសនាបោះឆ្នោតសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

**មាត្រា ៤៣.–**

ការឃោសនាបោះឆ្នោត មានគោលបំណងបង្កលក្ខណៈឱ្យបេក្ខជន និងគណបក្សនយោបាយដែលចូលរួមប្រកួតប្រជែងនៅក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាធ្វើការផ្សព្វផ្សាយនូវគោលនយោបាយនិងកម្មវិធីនយោបាយរបស់ខ្លួនដល់អ្នកបោះឆ្នោត ។

**មាត្រា ៤៤.–**

សកម្មភាពការឃោសនាបោះឆ្នោត ត្រូវធ្វើឡើងក្នុងរយៈពេលដប់ប្រាំ(១៥)ថ្ងៃជាប់ៗគ្នា ហើយត្រូវបញ្ចប់ម្ភៃបួន (២៤) ម៉ោងមុនថ្ងៃបោះឆ្នោត ។

**មាត្រា ៤៥.–**

ក្នុងពេលឃោសនាបោះឆ្នោត និងពេលបោះឆ្នោត គណបក្សនយោបាយទាំងអស់ បេក្ខជនទាំងអស់ អ្នកបោះឆ្នោតទាំងអស់ សមាជិកនៃគណបក្សនយោបាយទាំងអស់ អ្នកគាំទ្រទាំងអស់ ត្រូវគោរពតាមវិធាន បទប្បញ្ញត្តិនិងគោលការណ៍ដែលចែងក្នុងច្បាប់នេះ ច្បាប់

ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងក្រមសីលធម៌ បទបញ្ជានិងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គោរពតាមគោលការណ៍សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

របៀប បែបបទប្តឹងជំទាស់ ឬ តវ៉ាក្នុងពេលឃោសនាបោះឆ្នោត និងការដោះស្រាយពាក្យបណ្តឹង ត្រូវកំណត់ដោយបទបញ្ជានិងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៤៦.-**

បទប្បញ្ញត្តិដូចមានចែងក្នុងជំពូកទី ៧ មាត្រា ៧១ មាត្រា ៧៤ មាត្រា ៧៥ មាត្រា ៧៦ មាត្រា ៧៧ មាត្រា ៨០ មាត្រា ៨១ មាត្រា ៨២ និងមាត្រា ៨៣ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវបានយកមកអនុវត្តសម្រាប់សកម្មភាពការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

## ជំពូកទី ៧
## ការបោះឆ្នោត

**មាត្រា ៤៧.-**

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលគ្មានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោតមិនមានសិទ្ធិបោះឆ្នោតបានឡើយ ។

**មាត្រា ៤៨.-**

អ្នកបោះឆ្នោតត្រូវទៅបង្ហាញខ្លួន និងត្រូវបោះឆ្នោតដោយខ្លួនឯងផ្ទាល់ នៅការិយាល័យបោះឆ្នោតដែលខ្លួនមានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការ ហើយត្រូវបង្ហាញឯកសារបញ្ជាក់អត្តសញ្ញាណរបស់ខ្លួនដល់មន្ត្រីការិយាល័យបោះឆ្នោត ។

**មាត្រា ៤៩.-**

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវធ្វើឡើងនៅក្នុងការិយាល័យបោះឆ្នោតមួយ ឬច្រើននៅថ្ងៃបោះឆ្នោត ។

**មាត្រា ៥០.-**

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវចាប់ផ្តើមពីម៉ោង ៧:០០ព្រឹក រហូតដល់ម៉ោង ១៥:០០ រសៀល ។

អ្នកបោះឆ្នោតដែលមានសិទ្ធិបោះឆ្នោត ហើយមានវត្តមាននៅក្នុងការិយាល័យបោះឆ្នោត ឬ បរិវេណខាងក្នុង នៅម៉ោង ១៥:០០ អាចបោះឆ្នោតក្រោយម៉ោង ១៥:០០ បាន ។

**មាត្រា ៥១.-**

អ្នកបោះឆ្នោតដែលមានបំណងបោះឆ្នោត មិនត្រូវអនុញ្ញាតឱ្យចូលក្នុងបរិវេណខាងក្នុងនៃការិយាល័យបោះឆ្នោតក្រោយម៉ោង ១៥:០០ បានឡើយ ។

ប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវប្រកាសបិទការបោះឆ្នោតនៅម៉ោង ១៥:០០ ។

**មាត្រា ៥២.-**

ប្រសិនបើអ្នកបោះឆ្នោតទាំងអស់ដែលមានឈ្មោះនៅក្នុងបញ្ជីបោះឆ្នោត បានបោះឆ្នោតរួចអស់ហើយ គណៈកម្មការការិយាល័យបោះឆ្នោតអាចប្រកាសបិទការបោះឆ្នោត ហើយបិទការិយាល័យបោះឆ្នោតមុនម៉ោង ១៥:០០ បាន ។

**មាត្រា ៥៣.-**

ដើម្បីបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អ្នកបោះឆ្នោតម្នាក់មានសិទ្ធិបោះឆ្នោតតែមួយសន្លឹក និងដោយខ្លួនឯងផ្ទាល់ សម្រាប់ក្រុមប្រឹក្សាប្រភេទនីមួយៗ ។

អ្នកបោះឆ្នោតម្នាក់ៗត្រូវបោះឆ្នោតដោយគូសសញ្ញានៅលើសន្លឹកឆ្នោត ដើម្បីជ្រើសរើសយកគណបក្សនយោបាយតែមួយគត់ដែលខ្លួនពេញចិត្ត និងគាំទ្រ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវកំណត់ដោយបទបញ្ជានិងនីតិវិធីនូវទម្រង់ សន្លឹកឆ្នោត និងរបៀបបោះឆ្នោត ។

**មាត្រា ៥៤.-**

គ្មានបុគ្គលណាម្នាក់ត្រូវបានអនុញ្ញាតឱ្យចូលទៅក្នុងការិយាល័យបោះឆ្នោតបានឡើយ

លើកលែងតែអ្នកត្រូវបោះឆ្នោត និងបុគ្គលដែលមានការអនុញ្ញាតពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៥៥.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវកំណត់បទបញ្ជានិងនីតិវិធីដើម្បីអនុញ្ញាតឱ្យអ្នកសង្កេតការណ៍ជាតិ អន្តរជាតិ និងភ្នាក់ងារគណបក្សនយោបាយសង្កេតមើលដំណើរការបោះឆ្នោត ។

**មាត្រា ៥៦.-**

ក្រោយពីបិទការបោះឆ្នោតភ្លាម គណៈកម្មការការិយាល័យបោះឆ្នោតត្រូវធ្វើកំណត់ហេតុអំពីដំណើរការបោះឆ្នោត ស្របតាមបទបញ្ជានិងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៥៧.-**

បទប្បញ្ញត្តិដូចមានចែងនៅក្នុងជំពូកទី ៨ មាត្រា ៨៨ថ្មី មាត្រា ៨៩ មាត្រា ៩០ មាត្រា ៩១ថ្មី មាត្រា ៩៥ មាត្រា ៩៦ មាត្រា ៩៧ ថ្មី មាត្រា ១០០ និងមាត្រា ១០១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវបានយកមកអនុវត្តចំពោះកិច្ចដំណើរការនៃការិយាល័យបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

## ផ្នែកទី ៨

## ការរាប់សន្លឹកឆ្នោត និងលទ្ធផលនៃការបោះឆ្នោត

**មាត្រា ៥៨.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវកំណត់ក្នុងបទបញ្ជានិងនីតិវិធីអំពីការរៀបចំ និងការគ្រប់គ្រងការិយាល័យរាប់សន្លឹកឆ្នោត និងការរាប់សន្លឹកឆ្នោតឱ្យស្របទៅតាមច្បាប់នេះ និងស្របទៅតាមបទប្បញ្ញត្តិដូចមានចែងក្នុងជំពូកទី ៨ មាត្រា ១០២ មាត្រា ១០៣ មាត្រា ១០៤ មាត្រា ១០៥ថ្មី មាត្រា ១០៧ និងមាត្រា ១០៨ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

**មាត្រា ៥៩.-**

ការិយាល័យបោះឆ្នោតក្លាយជាការិយាល័យរាប់សន្លឹកឆ្នោត នៅពេលរាប់សន្លឹកឆ្នោត ។

គណៈកម្មការការិយាល័យបោះឆ្នោត ក្លាយជាគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោត នៅពេលរាប់សន្លឹកឆ្នោត ។

**មាត្រា ៦០.-**

បន្ទាប់ពីគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោតបានបញ្ចប់ការរាប់សន្លឹកឆ្នោតភ្លាម គណៈកម្មការនេះ ត្រូវបិទផ្សាយលទ្ធផលបណ្ដោះអាសន្ននៃការរាប់សន្លឹកឆ្នោតតាមប្រភេទក្រុមប្រឹក្សានីមួយៗ ។

គណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោត ត្រូវធ្វើកំណត់ហេតុអំពីការរាប់សន្លឹកឆ្នោតនេះជាបី(០៣) ច្បាប់ មួយច្បាប់ផ្ញើជូនគណៈកម្មការរាជធានីរៀបចំការបោះឆ្នោត ឬ គណៈកម្មការខេត្តរៀបចំការបោះឆ្នោត ដោយភ្ជាប់ជាមួយនូវបញ្ជីបោះឆ្នោត សន្លឹកឆ្នោតបានការ សន្លឹកឆ្នោតមិនបានការ សន្លឹកឆ្នោតដែលពុំបានប្រើប្រាស់ បណ្ដឹងជំទាស់ ឬ តវ៉ា ប្រសិនបើមាន និងឯកសារផ្សេងៗទៀតមួយច្បាប់ផ្ញើជូនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងមួយច្បាប់បិទនៅការិយាល័យបោះឆ្នោត ។

កំណត់ហេតុនៃការរាប់សន្លឹកឆ្នោតនេះ ត្រូវចុះហត្ថលេខាដោយប្រធាន និងសមាជិកគណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោត ។ តំណាងគណបក្សនយោបាយអាចចុះហត្ថលេខាជាសាក្សីលើកំណត់ហេតុនេះបាន ។

**មាត្រា ៦១.-**

គណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោតត្រូវបញ្ជូនឯកសារលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាទៅគណៈកម្មការរាជធានីរៀបចំការបោះឆ្នោត ឬ គណៈកម្មការខេត្តរៀបចំការបោះឆ្នោត តាមបទបញ្ជា និងនីតិវិធីដែលបានកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៦២.-**

គណៈកម្មការរាជធានីរៀបចំការបោះឆ្នោត ឬគណៈកម្មការខេត្តរៀបចំការបោះឆ្នោត ត្រូវត្រួតពិនិត្យបញ្ជាក់និងបូកសរុបលទ្ធផលបណ្ដោះអាសន្នតាមមណ្ឌលបោះឆ្នោតនីមួយៗ ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ក្នុងរយៈពេលយ៉ាងយូរប្រាំ (០៥) ថ្ងៃ បន្ទាប់ពីថ្ងៃបោះឆ្នោត ។

**មាត្រា ៦៣.-**

គណៈកម្មការរាជធានីរៀបចំការបោះឆ្នោត ឬ គណៈកម្មការខេត្តរៀបចំការបោះឆ្នោត ត្រូវធ្វើកំណត់ហេតុនៃការត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលនេះជាបី(០៣) ច្បាប់ មួយច្បាប់ផ្ញើជូនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មួយច្បាប់បិទផ្សាយនៅគណៈកម្មការរាជធានីរៀបចំការបោះឆ្នោត ឬ គណៈកម្មការខេត្តរៀបចំការបោះឆ្នោតនិងមួយច្បាប់រក្សាទុកជាឯកសារ ។

**មាត្រា ៦៤.-**

បន្ទាប់ពីបានត្រួតពិនិត្យបញ្ជាក់ និងបូកសរុបលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតតាមមណ្ឌលបោះឆ្នោតនីមួយៗ និងដោះស្រាយបណ្ដឹងនៅថ្នាក់របស់ខ្លួនចប់សព្វគ្រប់ គណៈកម្មការរាជធានីរៀបចំការបោះឆ្នោត ឬ គណៈកម្មការខេត្តរៀបចំការបោះឆ្នោតត្រូវធ្វើការកំណត់ចំនួនអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ បានទទួល និងស្រង់ឈ្មោះបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សាតាមប្រភេទនីមួយៗ ស្របតាមបញ្ញត្តិច្បាប់នេះ និងច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

**មាត្រា ៦៥.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវត្រួតពិនិត្យ និងបញ្ជាក់លើលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាតាមប្រភេទនីមួយៗ ផ្អែកតាមបែបបទ និងទម្រង់ដែលកំណត់ដោយបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៦៦.-**

ក្នុងករណីមានការតវ៉ាក្នុងពេលបោះឆ្នោត និង/ ឬ ក្នុងពេលរាប់សន្លឹកឆ្នោត ហើយអ្នកប្តឹងតវ៉ាមិនពេញចិត្តនឹងការសម្រេចរបស់ប្រធានការិយាល័យបោះឆ្នោត ឬ ការិយាល័យរាប់សន្លឹកឆ្នោត អ្នកប្តឹងតវ៉ានោះអាចប្តឹងតវ៉ាទៅគណៈកម្មការរាជធានីរៀបចំការបោះឆ្នោត ឬ គណៈកម្មការខេត្តរៀបចំការបោះឆ្នោត រយៈពេលពីរ (០២) ថ្ងៃ យ៉ាងយូរបន្ទាប់ពីថ្ងៃបោះឆ្នោត និង/ ឬ រាប់សន្លឹកឆ្នោត ។

ជនដែលមានសិទ្ធិបោះឆ្នោតក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬ តំណាងគណបក្សនយោបាយ ដែលមានបញ្ជីបេក្ខជនឈរឈ្មោះ មានសិទ្ធិប្តឹងតវ៉ាទៅគណៈកម្មការរាជធានីរៀបចំការបោះឆ្នោត ឬ គណៈកម្មការខេត្តរៀបចំការបោះឆ្នោត អំពីលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាតាមប្រភេទនីមួយៗ ក្នុងរយៈពេលយ៉ាងយូរពីរ (០២) ថ្ងៃ បន្ទាប់ពីបិទផ្សាយលទ្ធផលបណ្តោះអាសន្ននៃការពោះឆ្នោតនៅការិយាល័យបោះឆ្នោត ។

គណៈកម្មការរាជធានីរៀបចំការបោះឆ្នោត ឬ គណៈកម្មការខេត្តរៀបចំការបោះឆ្នោតត្រូវដោះស្រាយបណ្តឹងតវ៉ា ក្នុងរយៈពេលយ៉ាងយូរបី (០៣) ថ្ងៃ បន្ទាប់ពីបានទទួលពាក្យបណ្តឹងតវ៉ា ។

ក្នុងករណីគណៈកម្មការរាជធានីរៀបចំការពោះឆ្នោត ឬ គណៈកម្មការខេត្តរៀបចំការពោះឆ្នោតបដិសេធបណ្តឹងតវ៉ា គណៈកម្មការរាជធានីរៀបចំការបោះឆ្នោត ឬ គណៈ-កម្មការខេត្តរៀបចំការបោះឆ្នោតត្រូវ :

-បំពេញបែបបទនៃការបដិសេធ ដោយបញ្ជាក់ពីមូលហេតុនៃការបដិសេធ ចុះហត្ថលេខា និងកាលបរិច្ឆេទ

-ផ្ញើសេចក្តីបដិសេធជូនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមួយច្បាប់ ជូនសាមីដើមបណ្តឹងមួយច្បាប់ និងរក្សាទុកមួយច្បាប់ជាឯកសារ ។

ក្នុងករណីគណៈកម្មការរាជធានីរៀបចំការបោះឆ្នោត ឬ គណៈកម្មការខេត្តរៀបចំការពោះឆ្នោតយល់ព្រមចំពោះបណ្តឹងតវ៉ា គណៈកម្មការរាជធានីរៀបចំការពោះឆ្នោត ឬ គណៈកម្មការខេត្តរៀបចំការពោះឆ្នោត ត្រូវបដិសេធលទ្ធផលបណ្តោះអាសន្ននៃការពោះឆ្នោតនៅការិយាល័យបោះឆ្នោតដោយ :

-ប្រកាសល្បូរលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតនៅការិយាល័យបោះ

ឆ្នោតនោះ ឬ ទាំងនោះត្រូវបានបដិសេធ

-បំពេញបែបបទនៃការយល់ព្រមតាមបណ្តឹង ដោយបញ្ជាក់ពីមូលហេតុនៃការបដិសេធ រួចហើយចុះហត្ថលេខា និងកាលបរិច្ឆេទ

-ប្រកាសថា សេចក្តីសម្រេចរបស់គណៈកម្មការរាជធានីរៀបចំការបោះឆ្នោត ឬគណៈកម្មការខេត្តរៀបចំការបោះឆ្នោតស្ថិតក្រោមការត្រួតពិនិត្យឡើងវិញដោយគណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោត

-ធ្វើសេចក្តីសម្រេច និងកំណត់ហេតុនៃការត្រួតពិនិត្យជូនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមួយច្បាប់ ក្នុងរយៈពេលយ៉ាងយូរម្ភៃបួន (២៤) ម៉ោង ដើម្បីឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រួតពិនិត្យឡើងវិញ

-ប្រគល់បែបបទនៃការបដិសេធលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជូនអ្នកប្តឹងតវ៉ាមួយច្បាប់ និងរក្សាទុកជាឯកសារមួយច្បាប់ ។

**មាត្រា ៦៧.-**

ក្នុងករណីអ្នកប្តឹងតវ៉ា មិនពេញចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មការរាជធានីរៀបចំការបោះឆ្នោត ឬ គណៈកម្មការខេត្តរៀបចំការបោះឆ្នោត អ្នកប្តឹងតវ៉ា ឬ តំណាងអាចប្តឹងទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងរយៈពេលយ៉ាងយូរបី (០៣) ថ្ងៃ បន្ទាប់ពីថ្ងៃទទួលបានបែបបទបដិសេធ ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវធ្វើការត្រួតពិនិត្យ និងសម្រេចទទួលយកលទ្ធផលនៃការបោះឆ្នោតនោះជាបានការ ឬ ឱ្យបោះឆ្នោតសាជាថ្មី ។

ជនដែលមានសិទ្ធិបោះឆ្នោតក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬ តំណាងគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះមានសិទ្ធិប្តឹងតវ៉ាទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអំពីលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាតាមប្រភេទនីមួយៗក្នុងរយៈពេលយ៉ាងយូរបី (០៣) ថ្ងៃ បន្ទាប់ពីថ្ងៃដែលគណៈកម្មការរាជធានីរៀបចំការបោះឆ្នោត ឬ គណៈកម្មការខេត្តរៀបចំការបោះឆ្នោតបិទផ្សាយលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតតាមប្រភេទក្រុមប្រឹក្សានីមួយៗ ។

ឆ្នោតនោះ ឬ ទាំងនោះត្រូវបានបដិសេធ

-បំពេញបែបបទនៃការយល់ព្រមតាមបណ្ដឹង ដោយបញ្ជាក់ពីមូលហេតុនៃការបដិសេធ រួចហើយចុះហត្ថលេខា និងកាលបរិច្ឆេទ

-ប្រកាសថា សេចក្ដីសម្រេចរបស់គណៈកម្មការរាជធានីរៀបចំការបោះឆ្នោត ឬគណៈកម្មការខេត្តរៀបចំការបោះឆ្នោតស្ថិតក្រោមការត្រួតពិនិត្យឡើងវិញដោយគណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោត

-ធ្វើសេចក្ដីសម្រេច និងកំណត់ហេតុនៃការត្រួតពិនិត្យជូនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមួយច្បាប់ ក្នុងរយៈពេលយ៉ាងយូរម្ភៃបួន (២៤) ម៉ោង ដើម្បីឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រួតពិនិត្យឡើងវិញ

-ប្រគល់បែបបទនៃការបដិសេធលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជូនអ្នកប្ដឹងតវ៉ាមួយច្បាប់ និងរក្សាទុកជាឯកសារមួយច្បាប់ ។

**មាត្រា ៦៧.-**

ក្នុងករណីអ្នកប្ដឹងតវ៉ា មិនពេញចិត្តនឹងសេចក្ដីសម្រេចរបស់គណៈកម្មការរាជធានីរៀបចំការបោះឆ្នោត ឬ គណៈកម្មការខេត្តរៀបចំការបោះឆ្នោត អ្នកប្ដឹងតវ៉ា ឬ តំណាងអាចប្ដឹងទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងរយៈពេលយ៉ាងយូរបី (០៣) ថ្ងៃ បន្ទាប់ពីថ្ងៃទទួលបានបែបបទបដិសេធ ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវធ្វើការត្រួតពិនិត្យ និងសម្រេចទទួលយកលទ្ធផលនៃការបោះឆ្នោតនោះជាបានការ ឬ ឱ្យបោះឆ្នោតសាជាថ្មី ។

ជនដែលមានសិទ្ធិបោះឆ្នោតក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬ តំណាងគណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះមានសិទ្ធិប្ដឹងតវ៉ាទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអំពីលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាតាមប្រភេទនីមួយៗក្នុងរយៈពេលយ៉ាងយូរបី (០៣) ថ្ងៃ បន្ទាប់ពីថ្ងៃដែលគណៈកម្មការរាជធានីរៀបចំការបោះឆ្នោត ឬ គណៈកម្មការខេត្តរៀបចំការបោះឆ្នោតបិទផ្សាយលទ្ធផលបណ្ដោះអាសន្ននៃការបោះឆ្នោតតាមប្រភេទក្រុមប្រឹក្សានីមួយៗ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL
ក្រសួងព្រះបរមរាជវាំង

**មាត្រា ៦៨.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវសម្រេចលើពាក្យបណ្តឹងតវ៉ាក្នុងរយៈពេលបី (០៣)ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង ។

ប្រសិនបើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតសម្រេចថា បណ្តឹងតវ៉ាមិនអាចទទួលយកបាន គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវ :

-បំពេញបែបបទនៃការបដិសេធ ដោយបញ្ជាក់ពីមូលហេតុនិងកាលបរិច្ឆេទនៃការបដិសេធ

-ផ្តល់សេចក្តីចម្លងនៃសេចក្តីបដិសេធមួយច្បាប់ទៅអ្នកប្តឹងតវ៉ា និង/ ឬ ទៅគណបក្សនយោបាយ

-រក្សាទុកសេចក្តីបដិសេធមួយច្បាប់ជាឯកសារ ។

**មាត្រា ៦៩.-**

ប្រសិនបើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតយល់ថា បណ្តឹងតវ៉ាមានទឡ្ហីករណ៍សមហេតុសមផល គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបើកសវនាការជាសាធា-រណៈក្នុងរយៈពេលយ៉ាងយូរបី (០៣) ថ្ងៃ ដើម្បីសម្រេច ។ ក្នុងករណីនេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្សព្វផ្សាយកាលបរិច្ឆេទ ទីកន្លែងនៃសវនាការ និងផ្តល់ព័ត៌មានទៅអ្នកប្តឹងតវ៉ា និង/ ឬ ទៅគណបក្សនយោបាយ ។

អ្នកប្តឹងតវ៉ា និង/ ឬ គណបក្សនយោបាយ និងសមាជិកគណៈកម្មការរៀបចំការបោះឆ្នោត និង/ ឬ គណៈកម្មការរៀបចំការបោះឆ្នោតដែលពាក់ព័ន្ធ ត្រូវមានវត្តមាននៅក្នុងសវនាការនេះ ។

ប្រសិនបើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតយល់ព្រមតាមពាក្យបណ្តឹង គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវ :

-បដិសេធលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ឬ នៅការិយាល័យបោះឆ្នោតទាំងនោះ ហើយរៀបចំឱ្យមានការបោះឆ្នោតសាជាថ្មីនៅកន្លែងនោះ ឬកន្លែងទាំងនោះក្នុងរយៈពេលប្រាំបី (០៨) ថ្ងៃយ៉ាងយូរ បន្ទាប់ពីការសម្រេចនេះ ដោយអនុលោមតាមបញ្ញត្តិ ដូចមានចែងក្នុងមាត្រា ៧៤ នៃច្បាប់នេះ

-បំពេញបែបបទនៃការយល់ព្រមបណ្តឹងតវ៉ាដោយបញ្ជាក់មូលហេតុនិងកាលបរិច្ឆេទនៃការយល់ព្រម

-ផ្តល់សេចក្តីចម្លងនៃសេចក្តីយល់ព្រមបណ្តឹងតវ៉ាមួយច្បាប់ទៅអ្នកប្តឹងតវ៉ា និង/ឬ គណបក្សនយោបាយ

-រក្សាទុកសេចក្តីចម្លងនៃសេចក្តីយល់ព្រមមួយច្បាប់ជាឯកសារ ។

ប្រសិនបើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ពុំយល់ព្រមតាមពាក្យបណ្តឹង គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវ :

-បំពេញបែបបទនៃការបដិសេធបណ្តឹងតវ៉ា ដោយបញ្ជាក់មូលហេតុ និងកាលបរិច្ឆេទនៃការបដិសេធ

-ផ្តល់សេចក្តីចម្លងនៃការបដិសេធមួយច្បាប់ទៅអ្នកប្តឹងតវ៉ា និង/ឬ គណបក្សនយោបាយ

-រក្សាទុកសេចក្តីចម្លងនៃការបដិសេធមួយច្បាប់ជាឯកសារ ។

សេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាសេចក្តីសម្រេចចុងក្រោយ ។

**មាត្រា ៧០.-**

បន្ទាប់ពីបានដោះស្រាយពាក្យបណ្តឹងតវ៉ារួចរាល់ហើយ និងបន្ទាប់ពីបានត្រួតពិនិត្យលទ្ធផលនៃការបោះឆ្នោតទាំងអស់ រួមទាំងលទ្ធផលនៃការបោះឆ្នោតសាជាថ្មី គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្សព្វផ្សាយលទ្ធផលជាផ្លូវការនៃការបោះឆ្នោត ។

**មាត្រា ៧១.-**

ផ្អែកតាមលទ្ធផលជាផ្លូវការនៃការបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវត្រួតពិនិត្យ និងប្រកាសចំនួនអាសនៈ និងបេក្ខជនជាប់ឆ្នោតនៅក្នុងក្រុមប្រឹក្សាឃុំ សង្កាត់នីមួយៗ ។

ROYAUME DU CAMBODGE · LE MINISTRE du PALAIS ROYAL

# ផ្នែកទី ៩

# ការបោះឆ្នោតសាជាថ្មី

**មាត្រា ៧២.-**

ការបោះឆ្នោតសាជាថ្មី ត្រូវធ្វើឡើងបន្ទាប់ពីកាលៈទេសៈមានអាសន្ន ។

កាលៈទេសៈមានអាសន្នអាចមានករណីណាមួយ ក្នុងចំណោមករណីដូចខាងក្រោម :

-អសន្តិសុខជាសាធារណៈ

-ទឹកជំនន់ ខ្យល់ព្យុះ រញ្ជួយផែនដី ឬ គ្រោះធម្មជាតិផ្សេងៗទៀត

-ការដួលរលំអគារសម្រាប់បម្រើការបោះឆ្នោតដោយយថាហេតុណាមួយ អគ្គិភ័យ ឬ ការខូចខាតប្រហាក់ប្រហែលគ្នាដែលនាំឱ្យមានគ្រោះថ្នាក់

-ការរាំងស្ទះផ្នែករដ្ឋបាលដែលមិនអាចឱ្យការបោះឆ្នោតដំណើរការបាន ។

**មាត្រា ៧៣.-**

ក្នុងករណីដែលកាលៈទេសៈមានអាសន្នដូចបានចែងក្នុងមាត្រា ៧២ នៃច្បាប់នេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវរាយការណ៍ភ្លាមជូននាយករដ្ឋមន្ត្រី ។

**មាត្រា ៧៤.-**

ក្នុងករណីដែលការិយាល័យបោះឆ្នោតណាមួយមានអាសន្នដូចមានចែងក្នុងមាត្រា ៧២ ឬ ករណីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បដិសេធលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតណាមួយដូចមានចែងក្នុងមាត្រា ៦៩ នៃច្បាប់នេះ ការបោះឆ្នោតនៅការិយាល័យនោះត្រូវធ្វើសាជាថ្មី ក្នុងរយៈពេលយ៉ាងយូរប្រាំបី(០៨) ថ្ងៃក្រោយ នៅទីកន្លែងសមស្របដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

អ្នកបោះឆ្នោតទាំងអស់ដែលមានសិទ្ធិបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះត្រូវអនុញ្ញាតឱ្យបោះឆ្នោត ទោះបីជាអ្នកទាំងនោះបានបោះឆ្នោតហើយក្តី ឬ មិនទាន់បានបោះឆ្នោតក្តី ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវធានាឱ្យមានសន្លឹកឆ្នោតគ្រប់ចំនួនដែលបោះពុម្ពលើក្រដាសពណ៌ផ្សេងពីលើកមុន ។

បែបបទនីតិវិធីនៃការបោះឆ្នោតសាជាថ្មី ត្រូវកំណត់ដោយបទបញ្ជានិងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

## ជំពូកទី ១០
## ការជាក់ជំនួសសមាជិកក្រុមប្រឹក្សា

**មាត្រា ៧៥.-**

ក្នុងករណីសមាជិកក្រុមប្រឹក្សាណាម្នាក់បានបាត់បង់សមាជិកភាពដូចមានចែងក្នុងមាត្រា ២២ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវជ្រើសរើសបេក្ខជន ដែលមានឈ្មោះក្នុងលេខរៀងលំដាប់បន្ទាប់ក្នុងបញ្ជីបេក្ខជនជាមួយមកជំនួសស្របតាមមាត្រា ២៣ នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដោយមិនចាំបាច់ធ្វើការបោះឆ្នោតឡើងវិញឡើយ ។

## ជំពូកទី ១១
## សមត្ថកិច្ចដោះស្រាយវិវាទក្នុងការបោះឆ្នោត

**មាត្រា ៧៦.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវសម្រេចលើវិវាទទាំងអស់ដែលពាក់ព័ន្ធទៅនឹងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

សេចក្ដីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាសេចក្ដីសម្រេចចុងក្រោយ ។

**មាត្រា ៧៧.-**

គណៈកម្មការការិយាល័យបោះឆ្នោត គណៈកម្មការការិយាល័យរាប់សន្លឹកឆ្នោត គណៈកម្មការក្រុង ស្រុក ខណ្ឌរៀបចំការបោះឆ្នោត គណកម្មការរាជធានីរៀបចំការបោះឆ្នោត គណៈកម្មការខេត្តរៀបចំការបោះឆ្នោត និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវដោះស្រាយការប្ដឹងតវ៉ា ឬ ប្ដឹងជំទាស់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវរៀបចំនីតិវិធីទាក់ទងទៅនឹងការប្តឹងតវ៉ា និងការប្តឹងជំទាស់នេះ ។

## ជំពូកទី ១២
## ការបោះឆ្នោតឡើងវិញ

**មាត្រា ៧៨.-**

ការរៀបចំធ្វើការបោះឆ្នោតឡើងវិញ ត្រូវធ្វើឡើងនៅក្នុងករណីណាមួយដូចខាងក្រោម :

-ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលបង្កើតថ្មីតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ៦ និង មាត្រា ៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-ក្រុមប្រឹក្សារាជធានី ឬ ខេត្ត ឬ ក្រុង ឬ ស្រុក ឬ ខណ្ឌ ដែលត្រូវរំសាយតាមល័ក្ខខ័ណ្ឌដូចមានចែងក្នុងមាត្រា ២៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

ការបោះឆ្នោតឡើងវិញសម្រាប់ជ្រើសរើសក្រុមប្រឹក្សាខេត្ត ក្រុង ស្រុក ខណ្ឌ ដែលបង្កើតថ្មី ត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរពីររយសែសិប(២៤០)ថ្ងៃ បន្ទាប់ពីការបង្កើតខេត្ត ក្រុង ស្រុក ខណ្ឌនោះ ។

ការបោះឆ្នោតឡើងវិញសម្រាប់ជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលត្រូវរំសាយតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងមាត្រា ២៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងយូរមួយរយម្ភៃ(១២០) ថ្ងៃ បន្ទាប់ពីត្រូវបានរំសាយ ។

កាលបរិច្ឆេទសម្រាប់ការបោះឆ្នោតឡើងវិញ ត្រូវកំណត់ដោយនាយករដ្ឋមន្ត្រីតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

**មាត្រា ៧៩.-**

ការបោះឆ្នោតឡើងវិញត្រូវប្រព្រឹត្តទៅក្រោមការគ្រប់គ្រង និងការចាត់ចែងរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អនុលោមទៅតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

**មាត្រា ៨០.-**

ក្រុមប្រឹក្សាដែលកើតឡើងដោយការបោះឆ្នោតឡើងវិញខាងលើនេះ មានអាណត្តិស្មើនឹងអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សានោះតែប៉ុណ្ណោះ ។

**មាត្រា ៨១.-**

ការបោះឆ្នោតឡើងវិញមិនត្រូវអនុញ្ញាតឱ្យធ្វើឡើយប្រសិនបើអាណត្តិដែលនៅសល់របស់ក្រុមប្រឹក្សាមានរយៈពេលមិនលើសពីមួយរយប៉ែតសិប(១៨០)ថ្ងៃ ។

ក្នុងរយៈពេលនេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ២៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

## ជំពូកទី ៣
## អំពីវិវាទ

**មាត្រា ៨២.-**

បទប្បញ្ញត្តិដែលចែងក្នុងមាត្រា ១២១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

## ជំពូកទី ៤
## អំពីទោសប្បញ្ញត្តិ

**មាត្រា ៨៣.-**

ទោសប្បញ្ញត្តិដូចមានចែងក្នុងជំពូកទី ១១ មាត្រា ១២៤ ថ្មី មាត្រា ១២៦ ថ្មី មាត្រា ១២៨ថ្មី មាត្រា ១២៩ ថ្មី មាត្រា ១៣០ ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តចំពោះការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

**មាត្រា ៨៤.-**

ត្រូវព្រមានចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៤៤ នៃច្បាប់នេះ ។

ក្នុងករណីដែលនៅពុំព្រមអនុវត្តតាម ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេលប្រាំ(០៥) ឆ្នាំ លុបបេក្ខភាពរបស់សាមីខ្លួន ឬ លុបបេក្ខភាពឈរឈ្មោះបោះឆ្នោត

របស់គណបក្សនយោបាយ និង/ឬត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលាន(៥.០០០.០០០) រៀលដល់ដប់លាន (១០.០០០.០០០) រៀល ។

**មាត្រា ៨៥.-**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីដប់លាន (១០.០០០.០០០)រៀល ទៅម្ភៃប្រាំលាន (២៥.០០០.០០០)រៀល ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត និង/ឬលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេលប្រាំ (០៥)ឆ្នាំ ចំពោះសមាជិកគណៈកម្មាធិការជាតិ សមាជិកគណៈកម្មការរាជធានី សមាជិកគណៈកម្មការខេត្ត សមាជិកគណៈកម្មការក្រុង ស្រុក ខណ្ឌរៀបចំការបោះឆ្នោត និងសមាជិកគណៈកម្មការការិយាល័យបោះឆ្នោត ដែលបន្លំឯកសារ បន្លំសន្លឹកឆ្នោត ឬ ប្រើកលល្បិចដើម្បីបន្លំលទ្ធផលនៃការបោះឆ្នោត ។

**មាត្រា ៨៦.-**

ត្រូវព្រមានចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ១០០ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ ក្នុងករណីដែលមិនព្រមអនុវត្តតាមការព្រមាននេះ ត្រូវឃាត់ខ្លួន និងដកហូតអាវុធសម្រាប់រយៈពេលសែសិបប្រាំបី (៤៨) ម៉ោង ដោយភ្នាក់ងារមានសមត្ថកិច្ច និងផ្តន្ទាទោសពិន័យជាប្រាក់ពីដប់លាន (១០.០០០.០០០)រៀល ដល់ហាសិបលាន (៥០.០០០.០០០) រៀល ។

ប្រសិនបើជនល្មើសនោះ ជាមន្ត្រីរាជការស៊ីវិល កងយោធពលខេមរភូមិន្ទ នគរបាលជាតិ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវ :

-ស្នើទៅប្រធានស្ថាប័នរបស់សាមីខ្លួន ដើម្បីឱ្យដាក់វិន័យរដ្ឋបាលចាប់ពីការដាក់ឱ្យនៅទំនេរដោយគ្មានបៀវត្សរហូតដល់ការបណ្តេញចេញពីមុខតំណែងយោលទៅតាមកម្រិតនៃបទល្មើស

-លុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ។

ប្រសិនបើជនល្មើសនោះជាភ្នាក់ងារ ឬ ជាសមាជិក ឬ ជាបុគ្គលិករបស់គណៈកម្មាធិការជាតិ ឬ គណៈកម្មការរាជធានី ឬ គណៈកម្មការខេត្ត ឬ គណៈកម្មការក្រុង ស្រុក ខណ្ឌរៀបចំការបោះឆ្នោត ត្រូវលុបឈ្មោះចេញពីការងារភ្លាម និងមិនឱ្យចូលបម្រើការងារជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬ គណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់

ថ្នាក់ សម្រាប់រយៈពេលដប់(១០)ឆ្នាំ ចាប់ពីសម័យបោះឆ្នោតនេះទៅ បន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងវាក្យខ័ណ្ឌទី ១ នៃមាត្រានេះ ។

**មាត្រា ៨៧.-**

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីប្រាំលាន (៥.០០០.០០០) រៀល ទៅដប់លាន (១០.០០០.០០០)រៀល ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត និង/ ឬ ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ចំពោះជនណា ឬ គណបក្សនយោបាយណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៤៥ នៃច្បាប់នេះ ឬ មាត្រា ៧៦ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

**មាត្រា ៨៨.-**

ត្រូវព្រមានចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៧៧ និងបទប្បញ្ញត្តិនៃមាត្រា ៧៨ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

ក្នុងករណីដែលនៅតែពុំព្រមអនុវត្តតាម ត្រូវលុបឈ្មោះពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេលប្រាំ(០៥)ឆ្នាំ និងត្រូវស្នើទៅប្រធានស្ថាប័នរបស់សាមីខ្លួនឱ្យដាក់វិន័យរដ្ឋបាល ចាប់ពីការដាក់ឱ្យនៅទំនេរដោយគ្មានបៀវត្ស រហូតដល់បណ្តេញចេញពីមុខតំណែងនិង/ ឬ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពីមួយលាន(១.០០០.០០០)រៀលដល់ពីរលាន(២.០០០.០០០) រៀល ។

# ជំពូកទី ៥

# អំពីអន្តរប្បញ្ញត្តិ

**មាត្រា ៨៩.-**

កាលបរិច្ឆេទនៃការបោះឆ្នោតលើកទី ១ដើម្បីជ្រើសរើសក្រុមប្រឹក្សា ត្រូវធ្វើឡើងក្នុងរយៈពេលដប់ពីរ(១២)ខែយ៉ាងយូរ បន្ទាប់ពីច្បាប់នេះចូលជាធរមាន ។

**មាត្រា ៩០.-**

ដើម្បីបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាលើកទី ១ ចំនួនសមាជិកក្រុមប្រឹក្សា ត្រូវ

កំណត់ក្នុងរយៈពេលយ៉ាងយូរមួយរយម្ភៃ(១២០)ថ្ងៃមុនថ្ងៃបោះឆ្នោត ដោយអនុលោមតាម មាត្រា ១៨ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។

## ជំពូកទី ៦

## អវសានប្បញ្ញត្តិ

**មាត្រា ៩១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៩២.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០០៨

៣រល.០៩០៥.៦០០

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**ហត្ថលេខា**

**ស ខេង**

លេខៈ ៥៥៧ ច.ល

**[illegible]ចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ[illegible] ឆ្នាំ២០០៨

**[illegible]រាជរដ្ឋាភិបាល**

**[illegible] ចិនកេន**